ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

"..... ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព"

លេខ : ......២៤៤៣...... បទ.វគ.ទ.ទ.

# រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
## ជំរាបមក
## លោកឧកញ៉ា លោកអគ្គនាយក លោក លោកស្រីប្រធានក្រុមហ៊ុន
## ផ្តល់សេវាទូរគមនាគមន៍

**កម្មវត្ថុ** : ស្តីពីការបង់ប្រាក់កក់ និងការផ្តល់គំរោងបច្ចេកទេស.គំរោងអាជីវកម្ម
( Operating Deposit, Technical Plan and Business Plan ) ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ សូមជំរាប លោកឧកញ៉ា លោកអគ្គនាយក លោក លោកស្រីប្រធានក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ទាំងអស់អោយបាន ជ្រាបថា : ដើម្បីអនុវត្តន៍តាមខ្លឹមសារអាជ្ញាប័ណ្ណផ្តល់សេវាទូរគមនាគមន៍ ដែលក្រសួងបានផ្តល់ជូនអោយ ក្រុមហ៊ុន ក្រសួងសូមលោកឧកញ៉ា លោកអគ្គនាយក លោក លោកស្រីប្រធានក្រុមហ៊ុនរួសរាន់ផ្តល់ជូនមក ក្រសួងនូវ :

- ប្រាក់កក់ធានាសំរាប់ប្រតិបត្តិការនៃការផ្តល់សេវាទូរគមនាគមន៍ ប្រាក់កក់ធានានេះត្រូវធ្វើ ការទូទាត់នៅនាយកដ្ឋានផែនការ-ហិរញ្ញវត្ថុនៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ រៀងរាល់ម៉ោងធ្វើការ ។
- គំរោងបច្ចេកទេស និងគំរោងអាជីវកម្ម ( Technical Plan and Business Plan ) ឯកសារនេះត្រូវផ្ញើមកក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ( អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ ) ។

ករណីលោកឧកញ៉ា លោកអគ្គនាយក លោក លោកស្រីប្រធានក្រុមហ៊ុនមិនគោរពតាមខ្លឹមសារ ខាងលើនេះ ក្រសួងនឹងមានវិធានការណ៍រឹងមាំអាចឈានដល់ធ្វើការដកហូតអាជ្ញាប័ណ្ណជាធរមាន ។

សូមលោកឧកញ៉ា លោកអគ្គនាយក លោក លោកស្រីប្រធានក្រុមហ៊ុនទទួលនូវការរាប់អាន ដ៏ស្មោះអំពីខ្ញុំ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៧

រ ដ្ឋ ម ន្ត្រី

សូរ-ឃុន

**ចម្លងជូន** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

" ដើម្បីជូនជ្រាប "
- ឯកសារ-កាលប្បវត្តិ